Free
សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

REMEDIUM PHARMACY
ឱសថស្ថានរ៉ឺមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម • ការវេចខ្ចប់ឱសថ • ការលាយផ្សំឱសថ
• បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ • ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071



សួស្ដី ឆ្នាំវកអដ្ឋស័កពស២៥៦០
Happy new year
Year of Monkey 2560
ចូលឆ្នាំវកអដ្ឋស័កពស២៥៦០នៅថ្ងៃព្រហស្បតិ៍
ទី១៤ខែមេសា ២០១៦ ម៉ោង២០:០០នាទី
ទេពធីតាឈ្មោះ កិរិណី យាងចុះមកផ្ដល់សេចក្ដី
សុខចំរើន សុភមង្គលដល់ជនរួមជាតិខ្មែរទាំងអស់។
សូមជូនពរមកជនរួមជាតិខ្មែរទាំងអស់ឱ្យបានសេចក្ដី
សុខចំរើន សុភមង្គល កុំបីខានឱ្យសោះ។

# ខ្មែរ_អាមេរិកាំងនៅឡូវែលតវ៉ានៅសាលាក្រុង

**ដោយ ពិន សំខុន**

ជាលើកដំបូងបង្អស់នៃប្រវត្តិក្រុងឡូវែលដែលក្រុមប្រឹក្សាសាលាក្រុងឡូវែលបានបោះឆ្នោតដើម្បីសហគមន៍ខ្មែរ-អាមេរិកាំងផ្ដល់"៨សម្លេងព្រម"នឹង"១សម្លេងអនុប្បវាទ"មិនទទួលបដិសណ្ឋារកិច្ចឧត្ដមសេនីយ ហ៊ុន ម៉ាណែត នាយអគ្គសេនាធិការរងនៃកងយោធពលខេមរភូមិន្ទជាកូនប្រុសច្បងរបស់លោកនាយករដ្ឋមន្ត្រីយូរអង្វែង ហ៊ុន សែន ដែលត្រូវមកដល់នាឱកាសចូលឆ្នាំថ្ងៃទី១៦-១៧មេសានឹងមិនទទួលយកអំណោយ "រូបចម្លាក់ព្រះបាទជ័យវរ្ម័នទី៧"នាំមកដោយឧត្ដមសេនីយដដែលនេះ។ ប្រជាពលរដ្ឋខ្មែរព្រមានជាង ៣០០នាក់ បានចេញមកធ្វើការតវ៉ាយ៉ាងកុះករ

**តទៅទំព័រទី ១១**

**Khmer Lowell Protested at City Hall - In English,** see page **28**

**By Pin Samkhon**



ការិយាល័យច្បាប់
រ៉ូសា និង តាំង

Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ស៊ីស្កូ ជេ.រ៉ូសា

Andrew ´Bunna´ Taing, Esq.
មេធាវី អែន ឌ្រីវប៊ុណ្ណា តាំង
Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
• Auto Accidents/ Personal Injury
• Bankruptcy
• Immigration
• Consumer Protection
• Real Estate Closings/Disputes
• Divorces Child Custody

តំណាងក្ដីដូចខាងក្រោម
• គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
• ក្ស័យធន
• អន្តោប្រវេសន៍
• ការពារអតិថិជន
• ទំនាស់ផ្នែកអចលនវត្ថុ
• លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com

The 6th Annual
KhmerPost USA
Media & Community Gala
Present Partners GREATER LOWELL CHAMBER OF COMMERCE UMASS LOWELL
APA Heritage Month Celebration
Friday, May 20, 2016
5:30p.m -10p.m
Sompao Meas Hall
450 Chelmsford St. Lowell, Massachusetts
Tickets info, please contact: Soben Pin 978-656-8141 or visit: www.khmerpost.us/gala-2016

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554
ឱសថស្ថាន សេនជ្វឹរ :
យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!


‣ ផ្ដល់សេវាដល់ទីលំនៅ
‣ ខ្ចប់ឱសថតាមបំណង
‣ ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត
937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476


រាត្រីសមោសរខ្មែរផុសស.រ.អា.ឆ្នាំទី៦
The 6th Annual
ខ្មែរផុស
KhmerPost USA
Media & Community Gala
Present Partner
GREATER LOWELL
CHAMBER OF COMMERCE
ដើម្បីរំលឹកទិវាកេរមរតកអាស៊ាន
-ប៉ាស៊ីហ្វិក អាមេរិកាំង
CELEBRATING ASIAN/PACIFIC
AMERICAN HERITAGE MONTH
FRIDAY, MAY 20TH, 2016
5:30PM-10PM
នៅភោជនីយដ្ឋាន សំពៅមាស
Sompao Meas Hall
450 Chelmsford St. Lowell, Massachusetts
Registration and Cocktail: 5:30PM
Cultural Performance and Dinner: 6:30PM
Speaking Engagement: 7:30PM
Admission $45.00/Person, Table of Ten $400.00
RSVP: SochetChhen: info@khmerpost.us | 978-677-7163
More information at: www.khmerpost.us/Gala

# ប្រកួតគ្នាទៅសេដ្ឋវិមាន
# Race to the Whitehouse

**ដោយ : ខ្មែរផុស.ស.រ.អា.**

គណបក្សអាមេរិកាំង២បន្តប្រកួតគ្នាដើម្បីដណ្តើមយកឈ្នះ នា"ស៊ូប័រធូសដេយ" ទី៥មេសា ជាថ្មីម្តងទៀត នៅ"រដ្ឋវីកុងសិន" ។ ខាងគណបក្សសាធារណរដ្ឋមាន ឌុណល់ ត្រម - ថេដ គ្រូស នឹង ខេស៊ីក រីឯខាងគណបក្សប្រជាធិបតេយ្យមាន ហ៊ីឡារី គ្លីងតុន នឹង បេនី សេនឌឺ ។ លទ្ធផលនៅរដ្ឋវីសកុងសិន នាវេលាម៉ោង១០យប់នោះមានដូចតទៅ:

១-ខាងគណបក្សប្រជាធិបតេយ្យៈគោលដៅគឺឱ្យបានដំណាង"ដេឡេគ្កេត": ២៣៣២

-បេនី សេនឌឺ ឈ្នះបាន ៣៤៨.៤០៦ សម្លេង គឺ ៥៥.៨% បានតំណាង "ដេឡេគ្កេត" សារ៉ុប១០៦១

-ហ៊ីឡារី គ្លីងតុន បាន ២៧៤.០៩៨ សម្លេង គឺ ៤៣.៩% បានតំណាង "ដេឡេគ្កេត" សារ៉ុប១៧៤៩

ថ្វីត្បិតតែ ហ៊ីឡារី មិនបានឈ្នះនៅ "វិសកុនស៊ិន"នេះក៏ដោយ ក៏ចំនួនតំណាងបានឡើង ទៅជិតដល់គោលដៅណាស់ទៅហើយ ដូច្នេះសេចក្តីសង្ឃឹមរបស់ បេនី សេនឌឺ ដែលជាអ្នកឈ្នះនាថ្ងៃនេះ នៅសល់តែតិចតួចប៉ុណ្ណោះ ហើយមណ្ឌលបោះឆ្នោតទៅថ្ងៃមុខ ក៏មាន"ដេឡេគ្កេត"ចំនួនច្រើន ដូចជា ញូយ៉ក ឬ កាលីហ្វ័រញ៉ា ជាដើមដែលជាកន្លែងខ្លាំងរបស់ ហ៊ីឡារី ផង។ ទំនងជា បេនី អាចនឹងដកខ្លួនមុនទៅជួប"មហាសន្និបាតបក្ស កុនវិនសិន" ផងក៏មិនដឹង។

២-ខាងគណបក្សសាធារណរដ្ឋៈ គោលដៅគឺឱ្យបានដំណាង"ដេឡេគ្កេត": ១២៣៧

១-ថេដ គ្រូស ឈ្នះបាន ៣៤៧.៧៣៥ សម្លេង គឺ ៥០.២% បានតំណាង "ដេឡេគ្កេត" សារ៉ុប" ៥១៧

២-ឌុណាល់ ត្រម បាន ២២៧.០៤៥ សម្លេង គឺ៣២.៨% បានដំណាង"ដេឡេគ្កេត"សារ៉ុប ៧៤៣


Ted Cruz - Republican


Donald Trumph - Republican


John Kesik Republican


Bennie Sender


Hilary Clinton

៣-ជន ខេស៊ីក បាន ១០០.៨៤៥ សម្លេង គឺ ១៤.៦% បានដំណាង"ដេឡេគ្កេត"សារ៉ុប ១៤៥

ដូចគ្នានឹង ហ៊ីឡារី ដែរ ថេដ គ្រូស បាន ឈ្នះនៅ"វីកុងស៊ីន"មែន តែបូកសារុបចំនួន "ដេឡិគ្កេត"ទៅនៅតែចាញ់ ឌុណល ត្រម ជាង ២០០"ដេឡេគ្កេត"ដដែល ។រីឯ ជន ខេស៊ីក បើទោះជាមិនមានសង្ឃឹមថា ឈ្នះក៏ដោយក៏នៅតែត្រដ៏បន្តឈរឈ្មោះដដែល។ ខាងគណបក្សសាធារណរដ្ឋមួយចំនួនយល់ថា ប្រយោគរបស់ ឌុណល ត្រម មានភាពតឹងតែងមិនគួរក្លាយជាដំណាងឱ្យគណបក្សសាធារណរដ្ឋទេ តែគេមិនដឹងធ្វើដូចម្តេច ដើម្បីបញ្ឈប់ ឌុណល ត្រម បាន - ដូច្នេះការបន្តរបស់ ជន ខេស៊ីក គឺគេអាចយល់ថា មានបំណងខ្ទាស់មិនឱ្យ ឌុណល ត្រម បាន "ដេឡេគ្កេត"គ្រប់ចំនួន១២៣៧ ដើម្បីឱ្យគេតែងតាំងបាន ។ នេះជាបច្ចេកទេសមួយ ដែលអាចធ្វើឱ្យ"មហាសន្និបាទកុនវិនសិន"អាចុចយកបេក្ខជនណាម្នាក់ក៏បាន ហើយគេអាចចុចបេក្ខជនផ្សេងពី ឌុណល ត្រម ផង។

**សន្និដ្ឋានៈ** ហ៊ីឡារី គ្លីងតុន ខាងគណបក្សប្រជាធិបតេយ្យកំពុងដឹកមុខ ចំនួន ១៧៤៣ "ដេឡេគ្កេត" ឌុណល ត្រម ខាងគណបក្សសាធារណរដ្ឋក៏កំពុងដឹកមុខដោយចំនួន"ដេឡេគ្កេត"៧៤៣នាក់ ៕



# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជា
ឱសថ
ស្ថានមួយ
ដែលអាចផ្តល់
ភាពជឿជាក់
ដល់គ្រួសារ
លោកអ្នក




យើងខ្ញុំ
សូមជូនពរ
មហាប្រសើរ
ដល់លោក
អ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ារ៉, និងកាតធានារ៉ាប់រង សុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្ញើថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។

ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

លេខទូរស័ព្ទ 978-455-6554

លេខហ្វាក់ 978-455-9476

937 Gorham St Lowell, MA, 01852






**ចូលចិត្តមនុស្ស!**

នេះជាមូលហេតុដែលនាំឲ្យ Fallon Health បានបើកដំណើរការ Summit ElderCare® ក្នុងទីក្រុង Lowell—ដើម្បីឲ្យយើងខ្ញុំអាចជួយដល់មនុស្សជាទីស្រឡាញ់ មិត្តភ័ក្តិ និងអ្នកជិតខាងរបស់លោកអ្នក ឲ្យអាចរស់នៅបានដោយឯករាជ្យ និងអាចរស់នៅក្នុងផ្ទះរបស់ខ្លួនបានក្នុងពេលមួយដ៏យូរដែលអាចធ្វើទៅកើត ។

Summit ElderCare គឺជាកម្មវិធីដែលរួមបញ្ចូលការថែទាំសុខភាពគ្រប់យ៉ាង ចំពោះមនុស្សចាស់ (Program of All-Inclusive Care for the Elderly -PACE) ដែលមានផ្តល់ជូនសេវាកម្មវេជ្ជសាស្ត្រ, ការជ្រោមជ្រែងផ្នែកសង្គមកិច្ច, ការធានារ៉ាប់រងសុខភាព និងការថែទាំតាមផ្ទះ ដើម្បីជ្រោមជ្រែងមនុស្សចាស់ ដែលចង់បន្តការរស់នៅក្នុងផ្ទះរបស់ខ្លួន ។

**សូមហៅទូរស័ព្ទដើម្បីមកទស្សនាមជ្ឈមណ្ឌល PACE Center ថ្មីរបស់យើងខ្ញុំដែលមានទីតាំងនៅក្នុងបរិវេណសហគមន៍ D'Youville Life & Wellness Community នៃទីក្រុង Lowell ។**

**យើងខ្ញុំជឿជាក់ថា លោកអ្នកពិតជា~~ចូលចិត្ត~~ ស្រឡាញ់ មជ្ឈមណ្ឌលនេះ!**

## Summit ElderCare

**1-866-737-9438 (TRS 711 – សម្រាប់អ្នកពិបាកស្តាប់)**

ថ្ងៃច័ន្ទ–សុក្រ, ពីម៉ោង 8 ព្រឹក–ម៉ោង 5 ល្ងាច

**summiteldercare.org/khmer**

fallonhealth

*គ្រប់សេវាកម្មថែទាំសុខភាពទាំងអស់ត្រូវតែផ្តល់ជូនដោយ ឬត្រូវបានអនុញ្ញាតដោយក្រុមពហុវិស័យរបស់ PACE (PACE Interdisciplinary Team) (លើកលែងតែចំពោះសេវាកម្មសង្គ្រោះបន្ទាន់) ។ សមាជិករបស់ PACE អាចត្រូវទទួលខុសត្រូវចំពោះការចំណាយណាមួយដែលមិនបានទទួលការអនុញ្ញាត ឬដែលនៅក្រៅកិច្ចព្រមព្រៀងសេវាកម្ម PACE ។*

16-679-019b_KH Rev. 00 2/16 AH12_16

# ដំណាងរដ្ឋសង្កាត់លេខ១៨នឹងបោះឆ្នោតសម្រាប់អាណត្តិថ្មី

នៅឡូវែលមានដំណាងរដ្ឋ៣រូបដែលត្រូវចូលទៅធ្វើការនៅសភារដ្ឋឯបូស្តុន ហើយការបោះឆ្នោតដែលយើងកំពុងផ្តោតអារម្មណ៍នេះសំដៅតែសង្កាត់លេខ១៨ដែលមានខ្មែរច្រើនបំផុតរស់នៅទីនោះ អ្នកដោះឆ្នោតបោះបានតែនៅសង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ៕


រ៉ាឌី ម៉ម


ខេមរា ខៃ


ចេត ឃីម


ដេវ អូឡូវីត

**ដោយ : ពិន សំខុន**

**ឡូវែលៈ** តែមួយភ្លែតសោះអាណត្តិឆ្នាំ២០១៥-១៦ លោក រ៉ាឌី ម៉ម ដែលបានក្លាយជា "តំណាងរដ្ឋម៉ាសាឈូសិត សម្រាប់សង្កាត់លេខ១៨" ឡូវែលនឹងត្រូវចប់នៅចុងឆ្នាំ២០១៦នេះ បន្ទាប់ពីធ្វើការបាន២ឆ្នាំ។ លោកគឺជាខ្មែរដំបូងបង្អស់សម្រាប់សហរដ្ឋអាមេរិកនេះ ដែលបានជាប់ឆ្នោតជាដំណាងរដ្ឋនៅសង្កាត់ដែលសម្បូរខ្មែរច្រើនជាងគេបង្អស់រស់នៅក្នុងរដ្ឋម៉ាសាឈូសិត។ នៅខែវិច្ឆិកា ២០១៦ខាងមុខ ប្រជាពលរដ្ឋខ្មែរអាមេរិកាំងនឹងត្រូវអញ្ជើញឱ្យទៅបោះឆ្នោតម្តងទៀត សម្រាប់ដំណែងដែលលោក រ៉ាឌី ម៉ម បានកាន់កាប់ពីរឆ្នាំមកហើយនោះ។

ជាថ្មីម្តងទៀត បេក្ខជនខ្មែរអាមេរិកាំង៣រូប នឹងអាមេរិកាំង១រូប បានចេញមុខមកហើយ ដើម្បីប្រកួតយកដំណែង១នេះ:

**១-** លោក រ៉ាឌី ម៉ម ជាដំណាងរដ្ឋកំពុងកាន់ដំណែងមកពីគណបក្សប្រជាធិបតេយ្យ

**២-** លោក ចេត ឃីម ធ្លាប់ឈរជាបេក្ខជនសមាជិកក្រុមប្រឹក្សាក្រុងឡូវែលពី២ឆ្នាំមុនមកពីគណបក្សប្រជាធិបតេយ្យ

**៣-** លោក ខេមរា ខៃ ធ្លាប់ឈរជាបេក្ខជនសមាជិកក្រុមប្រឹក្សាសាលារៀនពីឆ្នាំមុនមកពីគណបក្សសាធារណរដ្ឋ ។

**៤-** លោក ដេវ អូឡូវីត ធ្លាប់ឈរជាបេក្ខជនតំណាងរដ្ឋសង្កាត់លេខ១៨ពី២ឆ្នាំមុនមកពីគណបក្សប្រជាធិបតេយ្យ ។

ចំណែកមនុស្សទី៥ ដែលគេរង់ចាំបេក្ខភាពរបស់ខ្លួនលោក ផលរដ្ឋា យ៉ែម ធ្លាប់ឈរជាបេក្ខជនដំណាងរដ្ឋកាលពីអាណត្តិមុនប្រឆាំងនឹងបេក្ខជន រ៉ាឌី ម៉ម ធ្លាប់ឈរជាបេក្ខជនសមាជិកក្រុមប្រឹក្សាក្រុង ទើបនឹងប្រកាសជាសាធារណថា "លោកបានធ្វើការចេចារជាមួយលោក រ៉ាឌី ម៉ម មិនឈរឈ្មោះទៅវិញដើម្បីបង្ហាញពីភាពមិនបែកបាក់របស់សហគមន៍ ហើយងាកមកគាំទ្របេក្ខភាពរបស់លោក រ៉ាឌី ម៉ម នឹងសូមអញ្ជើញនឹងប្អូននឹងមិត្តភក្រ្តឱ្យបោះឆ្នោតឱ្យ រ៉ាឌី ម៉ម"ទៀត ផង។ គេនៅចងចាំនៅឡើយថា កាលពីលើកមុនបេក្ខជន រ៉ាឌី ម៉ម បានចេញធ្វើការឃោសនាយ៉ាងតឹងតែងនឹងបកអាក្រាតយ៉ាងកាចសាហាវចំពោះ បេក្ខជន ផលរដ្ឋា យ៉ែម - មិនដឹងថាតើការអញ្ជើញរបស់លោក ផលរដ្ឋា យ៉ែម អាចមានឥទ្ធិពលលើអ្នកបោះឆ្នោតរបស់ខ្លួនដែរឬក៏អត់ទេ? រីឯលោក រ៉ាឌី ម៉ម ខ្លួនឯងនៅពេលបានឈ្នះឆ្នោតលើ ផលរដ្ឋា យ៉ែម ក្លាយជាសមាជិកសភារដ្ឋនាពេលនោះ ក៏បានទៅសម្តែងការគួរសមភ្លាមចំពោះរដ្ឋាភិបាលខ្មែរលោក ហ៊ុន សែន បានធ្វើឱ្យអ្នកបោះឆ្នោតឡូវែលរបស់ខ្លួនមួយចំនួនមានការខកចិត្តច្រើនទៅវិញ។

**គួរដឹងផងដែរថា :**

**ក-**របៀបបោះឆ្នោតលើកនេះ គេអាចគូសឈ្មោះបានតែម្នាក់ទេ នៅលើក្រដាសបោះឆ្នោត

**ខ-**បេក្ខជនខាងគណបក្សប្រជាធិបតេយ្យត្រូវប្រកួតប្រជែងជាមួយបេក្ខជន គ្នាឯងជាមុន

**គ-**បេក្ខជនដែលឈ្នះតែម្នាក់ខាងគណបក្សប្រជាធិបតេយ្យនឹងទៅប្រកួតជាមួយគណបក្សសាធារណរដ្ឋយកឈ្នះតែម្នាក់គត់ ។


រដ្ឋា យ៉ែម


Cambodian American Group Discussions

Help Your Community and Help Yourself

**What:** The Cambodian Mutual Assistance Association is teaming up with Associate Professor Leland Ackerson from UMass Lowell for a research study. We would like to talk with Cambodian Americans about the strengths and needs of the Greater Lowell Cambodian Community in order to improve our services.

**Who:** Cambodian Americans who immigrated to the US when they were age 15 or younger. Study participants must be age 18 or older, fluent in English, and willing to share their ideas and experiences in a focus group discussion.

**Where:** The discussions will take place at the CMAA office at 465 School Street in Lowell.

**When:** Cambodian American women: Saturday, April 16 at 11:30-1 or Thursday, April 28 at 5:30-7:00PM

Cambodian American men: Thursday, April 14 at 5:30-7:00PM or Saturday, April 30 at 11:30-1

**Thank you!** We will provide you with a meal and a $25 gift card to Target department stores as an appreciation of your time.

**To sign up:**
Contact Hannah Phan at CMAA, 978-454-6200, hphan@cmaalowell.org

**To find out more:**
Contact Associate Professor
Leland Ackerson at UMass Lowell
Leland_Ackerson@uml.edu
978-934-3128

www.uml.edu www.cmaalowell.org





Clemente Park Chiropractic





Chetra A. Keo, D.C.

851 Middlesex Street. Lowell, MA 01851
(978) 937-1492

Treatments

- Neck Pain • ឈឺ-ក
- Back Pain • ឈឺខ្នង
- Lower Back Pain • ឈឺចង្កេះ-ខ្នង

- Automobile Injuries • គ្រោះថ្នាក់រថយន្ត
- Personal Injuries • រងរបួស
- Work Related Injuries • របួសនៅកន្លែងធ្វើការ

# ប្រទេសភូមា: អូនសាំន ស៊ូជី ទទួលតួនាទីដូចនាយករដ្ឋមន្ត្រី

## Myanmar: Aung San Suu Kyi to get PM like role

Author: Elsie Buchanan Apr 02, 2016,

លោកស្រី អូនសាំន ស៊ូជី បានឡើងកាន់ដំណែងជាប្រធានក្រុមប្រឹក្សារដ្ឋនឹងជារដ្ឋមន្ត្រីក្រសួងកិច្ចការបរទេសភូមាដែលមានតួនាទីស្មើនឹងនាយករដ្ឋមន្ត្រីដ៏មានអំណាចបំផុត ដោយសារដំណាងលោកស្រីជាអ្នកឡើងកាន់ដំណែងជាប្រធានាធិបតីថ្មីនៃប្រទេសភូមាជាស៊ីវិលដំបូងបង្អស់ជំនួសលោកស្រីដែលជាប្រធានគណបក្ស "សម្ព័ន្ធជាតិដើម្បីប្រជាធិបតេយ្យ" ។ ស៊ូជី បានត្រូវអំណាចច្បាប់រដ្ឋធម្មនុញ្ញខាឃាំងមិនឱ្យធ្វើជាប្រធានាធិបតីបានដោយសារលោកស្រីមានប្តីនឹងកូនមិនមែនជាជនជាតិភូមា។ លោកស្រីបានថ្លែងជា ច្រើនដងថា "លោកស្រីនឹងនៅពីក្រោយខ្នងអំណាចប្រទេសភូមា រហូតដល់មានការកែប្រែច្បាប់ជាធរមានដែលនឹងអាចឱ្យលោកស្រីឡើងកាន់ដំណែងដ៏ខ្ពស់បំផុតនោះបាន" ។

កាលពីថ្ងៃទី១មេសាមិត្តដ៏ជំនិតរបស់លោកស្រី ស៊ូជី គឺលោក ទីន គីយ៉ាវ មិត្តដ៏យូរអង្វែងម្នាក់ធ្លាប់ជាមិត្តរួមថ្នាក់នៅមហាវិទ្យាល័យ "អុកស្វ៊ត" ប្រទេសអង់គ្លេសបានត្រូវប្រកាសជាប្រធានាធិបតីថ្មី ដោយប្រធានរដ្ឋសភា អ៊ូម៉ាន់វិន ខាំង ជាដំណោះស្រាយសន្តិវិធីដ៏ប្រសើបំផុត ដែលបានរកឃើញ ដើម្បីបញ្ចប់អំណាច៥០ឆ្នាំរបស់រដ្ឋបាលយោធានិយមបានដោយគ្មានបង្ហូរឈាមលោកអតីត





ប្រធានាធិបតីឧត្តមសេនីយ ធាន សែន ក៏បានប្រគល់ដំណែងរួចហើយដែរ ។ អនុប្រធានាធិបតីទី១ថ្មី គឺឧត្តមសេនីយ ធីន ស្វេ មកពីកូតាយោធា នឹងអនុប្រធានាធិបតីទី២ គឺលោក ហិនរី វ៉ាន់ជោ មកពីខាងខុំណាងឱ្យក្រុមជនជាតិភាគតិច។ មានសម្លេងក្នុងរដ្ឋសភា២៥%នឹងកាន់កាប់ដំណែងក្នុងក្រសួងសំខាន់៧៣ ធ្វើឱ្យក្រុមប្រឹក្សាយោធានៅមានអំណាចខ្លាំងខ្លានៅឡើយ រហូតដល់អាចមានដាក់ "វ៉េតូ" អាចទប់ស្កាត់បំណង ស៊ូជី ក្នុងការកែរទម្រង់រដ្ឋធម្មនុញ្ញ នាថ្ងៃខាងមុខបាន។

អូនសាំន់ ស៊ូជី កើតនៅថ្ងៃទី១៩ មិថុនា ១៩៤៥ជំនាន់អនានិគមអងគ្លេសជាកូនស្រីរបស់អនុសេនីយឯក ជា "វិរបុរសបិតាឯករាជ្យជាតិ" អូនសាំន ដែលបានយកឯករាជ្យជាតិមកជូនប្រទេសភូមាកាលពីជាង៥០ឆ្នាំមុន តែត្រូវគេលួចសម្លាប់នៅពេលលោកឈ្នះឆ្នោតមិនទាន់ទាំងបានកាន់អំណាចផង។ ស៊ូជី បានរៀនចប់មហាវិទ្យាល័យ "ដែលី" ឆ្នាំ៦០ ចប់មហាវិទ្យាល័យ "អុកហ្វត" ឆ្នាំ ១៩៦៤ បន្ទាប់មកទៅធ្វើការនៅអង្គការសហប្រជាជាតិ៣ឆ្នាំមុននឹងរៀបការមានប្តីជាតិអង់គ្លេសនៅឆ្នាំ១៩៧២ បានកូន២នាក់ ។ ឆ្នាំ១៩៨៨ ស៊ូជី បានត្រឡប់មកមាតុប្រទេសវិញ ធ្វើជាអគ្គលេខាធិការគណបក្ស "សម្ព័ន្ធជាតិដើម្បីប្រជាធិបតេយ្យ" ឆ្នាំ១៩៩០បានចូលរួមការបោះឆ្នោតឈ្នះឆ្នោតនៅសភាជាតិ៨១% តែក្រុមបក្សយោធាបានលុបចោលលទ្ធផលនៃជ័យជំនះនោះ ចាប់ ស៊ូជី (ដាក់គុកសារជាថ្មី) ។ នាពេលនោះ សហគមន៍អន្តរជាតិបានដាក់ទណ្ឌកម្មរដ្ឋបាលភូមាដោយសារមិនបានរៀបចំប្រទេសឱ្យស្របលទ្ធិប្រជាធិបតេយ្យនឹងមានការគោរពសិទ្ធមនុស្សគ្រប់គ្រាន់ដោយមិនឱ្យចូលជាសមាជិកអាស៊ានមិនឱ្យចេញផលិផលចូលទៅផ្សារសេរី អឺរ៉ុប នឹងអាមេរិក។ ក្រោយពីការដោះលែង ស៊ូជី ឱ្យមានសេរីភាព ឆ្នាំ២០១០ ស៊ូជី ក៏ចូលរួមបោះឆ្នោតតំបន់ម្តងទៀត បានជ័យជំនះ យកអាសនៈបាន៤៣ ក្នុងចំណោម៤៥អាសនៈដែលទំនេរ -ស៊ូជី ក៏បានក្លាយជាសមាជិកសភានៅពេលនោះ។ ឆ្នាំ២០១៥ គណបក្ស ស៊ូជី ចូលរួមបោះឆ្នោតសាកលជាថ្មីម្តងទៀត លើកនេះទទួលជ័យជំនះបានអាសនៈសភាជាតិ៨៦%ទាំងសភាជាន់ខ្ពស់នឹងសភាជាន់ទាបអនុញ្ញាត្តិឱ្យ ស៊ូជី តែងតាំងប្រធានាធិបតីយ នឹងអនុប្រធានាធិបតីទី២របស់ខ្លួនដែលទើបនឹងទទួលការដំណែង កាលពីថ្ងៃទី១នេះ។ ស្ថានភាពថ្មីនឹងធ្វើឱ្យប្រទេសភូមា

តទៅទំព័រទី ១០




ពិធីបុណ្យចូលឆ្នាំខ្មែរ
ព.ស.២៥៥៩ គ.ស.2016
YEAR OF THE MONKEY
CAMBODIAN NEW YEAR CELEBRATION
FREE EVENT
Saturday, April 23, 2016 12pm - 5pm
Pailin Volleyball Complex at Clemente Park
803 Middlesex St., Lowell, MA 01851
You are invited to celebrate the Cambodian New Year at Clemente Park!
Event Highlights:
Get a copy of Cambodian Music Artist Laura Mam's CD, "In Search of Heroes"
Live band Performance by Khemerak Band
Traditional Folk Games
Angkor Dance Troupe Performance
Food Trucks and Food Vendors
Tapestry Project by Lowell National Historical Park
Merchandise and Information Booths
Spoken Word Poetry by Princess Moon
Modern Dance Performance by SFC (Strive for Change)
Lifestyle
This is a free event put together by the Khmer New Year Planning Committee and Volunteers. We would like to wish you a Happy New Year, the Year of the Monkey!
Volunteers Needed - Email: Volunteer.ClementePark@gmail.com
Facebook Event Link: https://www.facebook.com/events/1517309741905460/
Gofundme Link: www.gofundme.com/KNY2016
For more information, please visit www.facebook.com/ClementeParkCommittee
សួស្តី ឆ្នាំ ថ្មី!
Happy Khmer New Year!
KHMER NEW YEAR
CLEMENTE PARK




# ទស្សនាប្រជុំកោះ ការ៉ាអ៊ីប(ភាគ៣)







**ដោយ សុបិន ពិន**

●●●នៅពេលសម្រាកហាលថ្ងៃ ខ្ញុំបានលះបង់ពីការគិតរកប្រាក់កំរៃប្រចាំថ្ងៃដែលជាការងាររបស់ខ្ញុំឈប់បានគិតពីការស្កាត់ទៅរកការជួបភ្ញៀវពាណិជ្ជកម្មឈប់គិតពីម៉ោងកូនចូលរៀន ឬក៏ចេញពីសាលាឈប់គិតពីធ្វើម្ហូបអាហារព្រឹកល្ងាច...អស់រលីងរស់នៅពាក់កណ្តាលការដេកលក់លង់នឹងការភ្ញាក់មិនបានឃើញពីមនុស្សចេញចូលប៉ុន្មានទេ ហើយអ្នកទាំងនោះក៏មិនខ្វាយខ្វល់ពីអ្នកណាមានសម្លៀកបំពាក់ហ៊ឹហាអ្វី ឬក៏គ្មានអ្វីក្រៅពីខោខ្លី ឬខោអាវសម្រាប់មុជទឹកយ៉ាងសាមញ្ញនោះដែរ។ មេឃជាទូទៅស្រឡះច្រើនជាងស្រទុំជួនកាលក៏មានភ្លៀងមួយភ្លែតដែរ តែពពកតិចតួចមិនអាចបិទបាំងលំហមេឃខៀវស្រងាត់ដ៏ធំធេងបានទេ ហើយពពកទាំងនោះ បើមើលយូរទៅវាគូសវាសជាគំនូរក្រវេមក្រវាមជារូបភាពដែលប្តូររូបរាងរាល់នាទី បើតាមដានវាហើយមិនចង់ឈប់ទេ។

ថ្ងៃទី៣នឹងទី៤ នៅលើ"កោះការីប៊ីន" ឬប្រទេស"ដូមីនិកាំនរេប៉ូប្លីក"មិនឆ្ងាយពីទីប្រជុំជន"សាំងដូមិងគោ"កម្មវិធីមិនសូវមានអ្វីផ្លាស់ប្តូរទេ ដោយសារតែយើងមិនចង់ទទួលយកអ្វីៗថ្មីៗ ដែលបុគ្គលិក "ភូមិបាយ៉ាព្រិនស៊ីព" ស្នើថែមទៀតតែប៉ុណ្ណោះ ម៉្លោះហើយភាពសម្រាកកាយភាពលំហែរនៅតាមមាត់សមុទ្ររលកតិចខ្យល់បក់ត្រ-សៀកនឹងចំហាយនៃកំដៅថ្ងៃជះមកលើរូបរាងកាយដែលមិនសូវមានអ្វីបិទបាំង ដូចតែគេឯងនៅទីនោះ នាំសេចក្តីស្រម័យទៅពិភពថ្មីមួយទៀតដែលមិនមាននរណាមើលអ្នកផ្សេងស្ងប់ស្ងាត់តែរៀងៗខ្លួនមិនខុសអ្វីពីពេលដែលយើងធ្វើ "សម្មាធិ"ជាច្រើនម៉ោងយ៉ាងពេញចិត្តនោះទេ។ ប្តីខ្ញុំគេចូលចិត្តនៅក្រោមឆ័ត្រ ប្រើកុំព្យូទ័រសម្រាប់សរសេរអត្ថបទមិនចេះចប់ស្លៀកខោខ្លីដងខ្លួនទទេ នៅមិនឆ្ងាយពីអាងហែលទឹកដែល ប៉ុណ្ណារ៉ូគេលេងទឹកជាមួយមិត្តក្មេងៗរបស់គេ។ ប៉ុណ្ណារ៉ូឥឡូវនេះ ហែលទឹកបានយ៉ាងចំណាប់ដោយមិនបាច់ប្រើពោងដូចពេលមុនទៀតទេ គេអាចហែលទឹកបានមួយជុំអាងដែលមានរាងក្រវិចក្រវ៉កមានចរន្តទឹកហូរតិចផង។

ទាំងពីព្រឹករហូតយប់សកម្មភាពកីឡាមានបន្តរជាហូរហែរមានការបង្ហាត់កីឡាក្នុងអាងទឹកក៏មានមានកីឡាបាល់ទាត់ ឬ "វ៉ូឡេយ" បាល់លើដីខ្សាច់ក៏មានមានការប្រណាំងជិះពោងក្នុងសមុទ្រជិះ "ស្គីលើទឹកសមុទ្រ" ក៏មានតែយើងមិនស្វែងរកអ្វីផ្សេងក្រៅតែពីសម្រាកនោះទេ។ ពេលរសៀលឡើងកម្មវិធីកំសាន្តថ្មីៗទៀត បានចាប់ផ្តើមជារៀងរាល់ពេលព្រលប់មានភ្លេងជាច្រើនវង់លេងភ្លេងនឹងច្រៀងកំដរភ្ញៀវយ៉ាងជំនាញមានការទទួលភេសជ្ជៈ"ខកថែល"ដល់គ្រប់ភ្ញៀវមានល្ខោនឬបញ្ចាំងកុន ឬ"កាណាវ៉ាល់"ឬក៏"លេងសៀក" ជារៀងរាលថ្ងៃ ដើម្បីកំដរភ្ញៀវជាកិត្តយស។ ខ្លះគេមកជាមួយគូរកំណាន់ក៏ទៅរកកន្លែងស្ងប់ស្ងាត់អង្គុយហូបអាហារក្រោមពន្លឺទៀនក្នុងពិភពសួគ៌ាយ៉ាងឯកោមានក្រុមតន្ត្រីមកកំដរតែ២នាក់ក៏បាន។ រាត្រីកាលក្រោមពន្លឺដួងចន្ទហ្វូងតារាព្រោងព្រាតមិនសូវមានន័យប៉ុន្មានទេ នៅទីនេះ គេណែនាំភ្ញៀវឱ្យទៅកំសាន្តកន្លែងដែលមានភ្លើងពណ៌មានក្លិនក្រអូបមានភ្លេងភ្លាត់មានអ្វីដែលសង្គមធម្មតាមិនធ្លាប់មាន ព្រោះទស្សនៈសេដ្ឋកិច្ចគេមិនទុកឱ្យមនុស្សនៅទំនេរមិនចាយលុយនោះទេ...សង្គមមួយទៀតនោះ គេឱ្យឈ្មោះថា ជីវិត "សម្បូរបែប" នៃ"វណ្ណៈមូលធននិយម" ដែលមិនមាននរណាពិន័យទោសពៃរ៍ តោះជាតិចតួចក៏គ្មានដែរ ពីព្រោះទីនេះគេហៅថា "សេរីភាព" គេមានតិចចាយតាមតិច **តទៅទំព័រទី ២២**





យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។
លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ MassHealth និងកម្មវិធី Medicare រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់ ដែលរួមមាន៖ *
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស) *
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប *
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SWH SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
1-888-566-3526 (ខ្សែទូរស័ព្ទឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

* លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014



MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- ច្បាប់ធានារ៉ាប់រង
- សំណងបុគ្គល
- ការរំលោភបទព្រហ្មទណ្ឌ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បំណុលអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com


តមកពីទំព័រទី ០៧
## ប្រទេសភូមា : អូន សានស៊ូជី ទទួលតួនាទី

បើកចំហរទំនាក់ទំនងសេដ្ឋកិច្ចនឹងសង្គមកិច្ចបានយ៉ាងពេញទំហឹងមកវិញជាមួយពិភពលោក។ ប្រធានាធិបតីអាមេរិកាំង បានសម្តែងការកោតសរសើរដល់ប្រធានាធិបតីថ្មីនៃប្រទេសភូមា "ដែលបានកសាងប្រវត្តិសាស្ត្រនៃអន្តរកាលដ៏រឹងមាំឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យដែលមានពលរដ្ឋស៊ីវិលដឹកនាំរដ្ឋាភិបាល"។

ការព្រួយបារម្ភ ថាសង្គ្រាមស៊ីវិលអាចនឹងកើតឡើងដោយសារក្រុមយោធាមិនព្រមបោះបង់អំណាចរបស់ខ្លួនបានត្រូវធានាដោយរចនាសម្ព័ន្ធថ្មីដែលអំណាចយោធានៅមានសែសសល់ក្នុងអំណាចថ្មីនៅឡើយ ហើយអាចការពារសុវត្ថិភាពម្នាក់ៗបានផង...មិនមាននយោបាយសងសឹកគ្នាផ្តល់សេចក្តីសង្ឃឹមដល់មនុស្សគ្រប់គ្នាបានប្រជាពលរដ្ឋភូមាកំពុងក៏ទទួលសំណាងប្រសើរបំផុត នាបច្ចុប្បន្នកាលថ្មីថ្មោងនេះ៕


ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

## តមកពីទំព័រទី ០៧ ខ្មែរ-អាមេរិកាំងនៅឡូវែល...

ក្នុងកិច្ចប្រជុំប្រចាំសប្ដាហ៍ពេញអង្គរបស់គណកម្មការសាលាក្រុងឡូវែល៩រូប ទាមទារឱ្យរដ្ឋាភិបាលក្រុងឡូវែលធ្វើសេចក្ដីសម្រេចចិត្តចំពោះការទទួលបរិសណ្ឋារកិច្ចចំពោះលោកឧត្តមសេនីយ ហ៊ុន ម៉ាណែត កាលពីថ្ងៃទី២៨ មិនា ឆ្នាំ ២០១៦។

ក្រុមបដិបក្ខ២ក្រុមបានមកបញ្ចេញមតិផ្ទុយគ្នាក្រុមទី១មានគ្នាប្រមាណ១០-២០នាក់គាំទ្រវត្តមានឧត្តមសេនីយ ហ៊ុន ម៉ាណែត សុំឱ្យសាលាក្រុងឡូវែលទទួលបដិសណ្ឋារកិច្ចនឹងឱ្យទទួលយករូបចម្លាក់ដែលកំពុងតែធ្វើដំណើរមកពីប្រទេសកម្ពុជាដោយមានបដារជាច្រើនបង្ហាញពីមតិរបស់ខ្លួនផង ក្រុមនេះដឹកនាំដោយគ្រួសារលោកអគ្គកុងស៊ុល អ៊ូ សុវណ្ណ ដែលមិនបានមកចូលរួមទេ មកតែភរិយា ហើយនឹងគ្រួសារលោកតុលា យុទ្ធ។ ក្រុមមួយទៀតប្រឆាំងនឹងវត្តមានកូនលោក ហ៊ុន សែន មានគ្នាប្រមាណ៣០០នាក់លើកបដារជាច្រើនបញ្ចេញមតិពីសកម្មភាពកូនលោក ហ៊ុន សែន នឹងឪពុករបស់គេកំពុងធ្វើនយោបាយអមនុស្សធម៌ផ្ដាច់ការនិយមនៅកម្ពុជានឹងបំណងពង្រីកវប្បធម៌នោះមកសហរដ្ឋអាមេរិក។ ខ្មែរ-អាមេរិកាំងជាង២០នាក់បានចុះឈ្មោះឡើងមកនិយាយពន្យល់អង្គប្រជុំក្រុមប្រឹក្សាក្រុងម្នាក់ម្ដងៗដែលនេះជាលើកដំបូងបង្អស់ដែលអ្នកគ្រប់គ្រងក្រុងឡូវែលបានយល់ពីបណ្ដាប្រជាពលរដ្ឋរបស់ខ្លួនបានច្រើនជាអតិមរមា។ អ្នកឡើងនិយាយមានជាអាទិ តុលា យុទ្ធ តំណាងឱ្យអ្នកគាំទ្រឱ្យ ហ៊ុន ម៉ាណែត មកឡូវែល រីឯខាងអ្នកមិនគាំទ្រមានជាអាទិ ខេមរា ខៃ ជាបេក្ខជនតំណាងរដ្ឋមកពីគណបក្សសាធារណរដ្ឋ អាដាមព្រិល ដំណាងពាណិជ្ជករ ចម្បា ប៉ាង ដំណាងឱ្យក្រុងខ្មែរ អ៊ុង ឫទ្ធី នឹង វាស្នា នួន ដែលជាអតីតសមាជិកក្រុមប្រឹក្សាក្រុងឡូវែលបានឡើងមកថ្លែងការពារគំនិតយោបល់តំណាងឱ្យក្រុមរៀងៗខ្លួនបានយ៉ាងច្បាស់លាស់ ។ អង្គប្រជុំប្រកបដោយអារម្មណ៍ចងចាំនូវព្រឹត្តិការណ៍នយោបាយចាស់នឹងថ្មីពីកម្ពុជាបានឆ្លើយតបទៅនឹងវាគ្មិនដែលឡើងមកថ្លែងការណ៍ ដោយទះដៃអបអរសាទរ ឬក៏ស្រែកចំអកទៅនឹងប្រយោគដែលប៉ះពាល់ដល់អារម្មណ៍ខ្លួនយ៉ាងខ្លាំងក្លាផ្អើលពេញសាលាក្រុងដែលបណ្ដាលឱ្យមានការព្រមានម្ដងម្កាលដោយអភិបាលក្រុងជាប្រធាននៃអង្គប្រជុំ។ បច្ចុប្បន្នអភិបាលក្រុង អេដវ៉ីត ខេណ្ណីឌី ឋិតនៅជាអជ្ញាកណ្ដាល ប៉ុន្តែអតីតអភិបាលក្រុង អេលីយ៉ុត រ៉ែតនីយ ដែលជាហត្ថលេខីនៃទីក្រុងភ្លោះភ្នំពេញ-ឡូវែល នឹង រីតា មើសៀ សមាជិកក្រុមប្រឹក្សាក្រុងដ៏មានប្រជាប្រិយភាពបំផុតបានផ្ដល់នូវអារម្មណ៍ផ្លាស់ប្ដូរមកគាំទ្រការសម្ដែងមតិដ៏ក្ដុកក្ដួលរបស់ពលរដ្ឋរងគ្រោះភាគច្រើនជាអតីតជនភៀសខ្លួនរស់នៅតំបន់របស់ខ្លួន។ ព្រឹត្តិការណ៍ដូចគ្នានេះ បានកើតកាលពី២សប្ដាហ៍មុននៅសហគមន៍ខ្មែរ-អាមេរិកាំងនៅរដ្ឋកាលីហ្វ័រញ៉ានាទីក្រុងឡុងប៊ិច ក៏បានបើកទំព័រប្រវត្តិសាស្ត្រថ្មីសម្រាប់ប្រជាពលរដ្ឋខ្មែរ-អាមេរិកាំងនៅទីនោះដែរ តែការតវ៉ានេះមិនមែនជាលើកទី១ទេ។

ព្រឹត្តិការណ៍ថ្ងៃទី២៨មិនានៅឡូវែលនេះបានកំណត់នូវការអនុវត្តន៍ដំណើរការនៃលទ្ធិប្រជាធិបតេយ្យយ៉ាងពេញទំហឹងរបស់សហគមន៍ខ្មែរ-អាមេរិកាំងដែលធ្វើឱ្យមានការភ្ញាក់ផ្អើលដល់សហគមន៍ខ្មែរឯទៀតៗនៅជុំវិញពិភពលោកសារព័ត៌មានក្នុងតំបន់ មានវិទ្យុ "WCAP" កាសែត "ឡូសាន់" ឬក្រៅតំបន់បានមកយកការណ៍ទៅផ្សព្វផ្សាយជាសាធារណនឹងជាព័ត៌មានក្ដៅ ដូចជា "អិនភីអរ NPR" ឬ "អេប៊ីស៊ី ABC" វិទ្យុ "វីអូអេ VOA" នឹង "អាស៊ីសេរី RFA" ជាដើម រួមទាំងកាសែត "ឌឹខេមបូឌាដេលិ TheCambodia Daily" នៅកម្ពុជា ក៏ចុះផ្សាយព័ត៌មាននេះយ៉ាងពិស្ដារដែរ។ ដំណើរការណ៍នេះបាននាំឱ្យសហគមន៍មានកម្លាំងកំហែងឡើងខ្លាំងជាងមុនដោយការសម្ដែងមតិមូលមាត់គ្នា ដើម្បីកសាងសង្គមដែលខ្លួនឯងរស់នៅឱ្យបានរីតតែប្រសើរឡើង ។ ការទាមទារនេះអមដោយមានសេចក្ដីសម្រេចប្រើ "ថ្នាំខ្លាំង" ដោយសាលាក្រុងអាមេរិកាំងជាលើកដំបូងនេះ គ្រាន់តែជាសញ្ញា "ចាប់ផ្ដើម" តែប៉ុណ្ណោះ ដែលនឹងមានឥទ្ធិពលនៅក្នុងតំបន់ផងនឹងជួយលើកទឹកចិត្តដល់សកម្មជននៅកម្ពុជាពីសកម្មភាពត្រឹមត្រូវដើម្បីប្រទេសរបស់ខ្លួនទៀតផង។

តើវានឹងផ្ដើមអ្វីខ្លះ? បញ្ហាជាច្រើនដែលមេដឹកនាំសហគមន៍បំរុងនឹងប្រឈមមុខដោះស្រាយជាបន្ត គឺសំអាតចរន្តអ្នកយកមុខមាត់ជាមួយ "ក្រុងភ្នំពេញ" ដោយយកក្រុងឡូវែលទៅប្រើជាឈ្នាន់។ នៅមានការជជែកគ្នាថែមទៀត ពីអ្នកដែលបានបង្ករឱ្យមានភាពស្មុគស្មាញពេញសហគមន៍ដោយយកអង្គការ ឬសមាគមមិនរកកម្រៃដែលខ្លួនកាន់កាប់ទៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួនជាច្រើនកន្លែងបណ្ដាលឱ្យសហគមន៍ខ្មែរនៅឡូវែលនេះទន់ខ្សោយជាយូរយាមកហើយ ។ ក្នុងសប្ដាហ៍បន្ទាប់ពីព្រឹត្តិកាណ៍ទប់ស្កាត់ទស្សនៈកិច្ច ហ៊ុន ម៉ាណែត មកទាំងពលរដ្ឋក្នុងសហគមន៍ទាំងក្រុមអ្នកដឹកនាំខ្មែរទាំងអភិបាលក្រុងកំពុងស្វែងរកយល់ពីវត្ថុបំណងពិតប្រាកដរបស់សហគមន៍ខ្មែរនៅឡូវែលដែលគេយល់ថា ទំនងជាមានការយល់ឃើញថា ពីពេលមុនអាចមានការភ័ណ្ឌច្រឡំ។

បាតុកម្មដែលមាន២ក្រុមប្រឈមមុខគ្នានេះប្រាកដជាមិនមែនជាការចងគំនុំនឹងខ្មែរគ្នាឯងទេ តែជាកិច្ចការពារសហគមន៍ដែលសម្បូរមនុស្សមកបោកប្រាស់យកចំណេញសម្រាប់តែផលប្រ-យោជន៍ខ្លួនឯង ។ អ្នកការពារគណបក្សប្រជាជនគួរតែយល់ថា ការពារនយោបាយដែលកំពុងអនុវត្តិន៍នៅភ្នំពេញ គឺការឱ្យគំរូ "គ្មានសីលធម៌" ដ៏អាក្រក់បំផុត បង្ហាញដល់បណ្ដាកូនចៅនៅទីនេះ ជាពិសេសនៅពេលដែលអ្នកនោះចង់ដើរតួជាដំណាងរបស់ពលរដ្ឋ ។ សាលាក្រុងបានធ្វើសេចក្ដីសម្រេចចិត្តយ៉ាងក្លាហាន ដើម្បីការពារសហគមន៍ខ្មែរនៅឡូវែលពីការបែកបាក់ពីភាពរងគ្រោះ គឺជាការស្រាយចំណងបញ្ហាដំបូងគេនៅពេលដែលពលរដ្ឋខ្មែរ-អាមេរិកាំងភាគច្រើនយល់ថា សាលាក្រុងបានចេញមុខធ្វើឱ្យពួកខ្លួនសប្បាយចិត្ត ៕























# ខ្មែរក្រោមនឹងចាប់ផ្តើមបោះពុម្ពឯកសារជាង៥ពាន់ទំព័រ នៅដើមខែមេសា

## The Khmer Kampuchea Krom to print more than 5,000 pages of founded documents in early April




**ភ្នំពេញៈ** ចាប់ពីថ្ងៃទី៤ ខែមេសា ខាងមុខនេះ សហគមន៏ខ្មែរកម្ពុជាក្រោមនឹងចាប់ផ្តើមបោះពុម្ពឯកសារជាង៥ពាន់ទំព័រដែលទាក់ទងនឹងប្រវត្តិទឹកដីកម្ពុជាក្រោម ។ ហើយសមាគមគ្រោងនឹងបញ្ចប់ការបោះពុម្ពនៅអំឡុងខែមិថុនា ឆ្នាំ២០១៥ ។ នេះបើតាមការបញ្ជាក់របស់លោក ថាច់ សេដ្ឋា ។ សហគមន៏ខ្មែរកម្ពុជាក្រោមនឹងចាប់បោះពុម្ពឯកសារដែលបានរកឃើញនៅប្រទេសបារាំងជាង៥ពាន់ទំព័រនៅដើមខែមេសាខាងមុខ ។ សហគមន៏ខ្មែរកម្ពុជាក្រោមលោក ថាច់ សេដ្ឋា បានឱ្យដឹងថា សព្វថ្ងៃនេះសមាគមខ្មែរក្រោមបានរៀបចំឯកសារនិងចរចាតម្លៃបោះពុម្ពរួចរាល់ ដើម្បីចាប់ផ្តើមបោះពុម្ពនៅថ្ងៃទី៤ ខែមេសា ។ លោកបានន្ថែមថា សមាគមត្រូវការថវិកាចំនួន១២៥០០អឺរ៉ូ ស្មើនឹង១៣០០០ដុល្លារអាមេរិក ដើម្បីថតចម្លងឯកសារសំខាន់ៗដែលទាក់ទងនឹងទឹកដីកម្ពុជាក្រោមប្រមាណ៥ពាន់ទំព័រនៅក្នុងប្រទេសបារាំងនោះ ។ លោកថាៈ "ឯកសារភាគច្រើនសរសេរជាភាសាបារាំង ហើយពេលនេះកំពុងធ្វើការថតចម្លងចេញពីសំណៅឯកសារដើម ។ ការថតចម្លងឯកសារទាំងនោះ មានតម្លៃ ២.៥០អឺរ៉ូ ក្នុងមួយទំព័រ ហើយសរុបទាំងអស់ជាង១២៥០០អឺរ៉ូ ស្មើជាង១៣០០០ដុល្លារអាមេរិក" ។ ប៉ុន្តែលោកថា សហគមន៏ខ្មែរកម្ពុជាក្រោមពុំមានថវិកាគ្រប់គ្រាន់សម្រាប់បោះពុម្ពឯកសារទាំងនោះឡើយ ។ លោកបញ្ជាក់ថាៈ "យើងត្រូវការការចូលរួមថវិកាពីបងប្អូនជនរួមជាតិ ព្រោះយើងមិនមានថវិកាគ្រប់គ្រាន់ទេ ។ ខ្ញុំសង្ឃឹមថា បងប្អូននឹងចូលរួមទោះបីជា១រយ២រយក៏ដោយ ព្រោះនេះជាឯកសារប្រយោជន៏ជាតិសម្រាប់ឱ្យកូនចៅជំនាន់ក្រោយបានសិក្សារៀនសូត្រ" ។ សហគមន៏ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីលទ្ធិប្រជាធិបតេយ្យបានរកឃើញឯកសារសំខាន់ៗទាក់ទងនឹងទឹកដីកម្ពុជាក្រោមប្រមាណ៥ពាន់ទំព័រនៅក្នុងប្រទេសបារាំង ។ ឯកសារទាំងនោះកំពុងត្រូវបានថតចម្លងចេញពីឯកសារដើមនៅក្នុងបណ្ណាសារដ្ឋានជាតិបារាំង នៅខេត្តអិកសង់ប្រូវ៉ង់ (Aix-en-Provence) ប្រទេសបារាំង ។ ឯកសារជាង៥ពាន់ទំព័រដែលនិយាយពីការផ្ទេរទឹកដីកម្ពុជាក្រោមទៅឱ្យប្រទេសវៀតណាមទាំងនោះ រួមមានព្រះរាជសារព្រះករុណាព្រះបាទនរោត្តមផ្ញើទៅរដ្ឋាភិបាលបារាំងកិច្ចព្រមព្រៀងបារាំងវៀតណាម នៅឆកសមុទ្រហាឡុង នៅដាឡាត់ និងនៅហ្សឺណែវ ប្អូជាដើម ។ លើសពីនេះ ក៏រកឃើញកំណត់ហេតុប្រជុំសភាបារាំងក្នុងការកាត់ទឹកដីខ្មែរឱ្យវៀតណាមថ្ងៃទី ០៤ មិថុនាឆ្នាំ១៩៤៩ សន្ធិសញ្ញាបារាំងវៀតណាម និងកំណត់ហេតុចរចាផ្សេងៗ ព្រមទាំងលិខិតឆ្លងឆ្លើយសម្ងាត់ដែលទាក់ទងនឹងការកាត់ផ្ទេរទឹកដីខ្មែរឱ្យវៀតណាមផងដែរ ។ ឯកសារទាំងនេះ ត្រូវបានរកឃើញនៅក្នុងបណ្ណាសារដ្ឋានជាតិបារាំង នៅខេត្តអិកសង់ប្រូវ៉ង់ (Aix-en-Provence) ប្រទេសបារាំង តាមការណែនាំរបស់ស្ថានទូតបារាំង ប្រចាំនៅកម្ពុជា ។ បើតាមប្រធានសហគមន៏ខ្មែរកម្ពុជាក្រោម បន្ទាប់ពីបញ្ចប់ការថតចម្លងសហគមន៏ខ្មែរកម្ពុជាក្រោមនឹងធ្វើការបកប្រែជាផ្លូវការនូវឯកសារទាំងនោះពីភាសាបារាំងមកជាភាសាខ្មែរ និងអង់គ្លេស ។ បន្ទាប់មកសហគមន៏ខ្មែរកម្ពុជាក្រោមនឹងដាក់ជូនទៅកាន់ក្រសួងអប់រំ ដើម្បីស្នើសុំបញ្ចូលក្នុងកម្មវិធីសិក្សា តម្កល់នៅរាជបណ្ឌិតសភាកម្ពុជា និងអង្គការយូណេស្កូ ដើម្បីរក្សាទុកជាប្រវត្តិសាស្ត្រជាតិ ។ គួររំលឹកថា កន្លងមកអ្នកនាំពាក្យស្ថានទូតវៀតណាមបានអះអាងជាសាធារណៈថា ទឹកដីកម្ពុជាក្រោមជារបស់វៀតណាមតាំងពីយូរយារណាស់មកហើយ ។ ដូច្នេះទើបធ្វើឱ្យសហគមន៏ខ្មែរកម្ពុជាក្រោមព្យាយាមធ្វើដំណើរទៅប្រទេសបារាំងស្រាវជ្រាវរកឯកសារ ដើម្បីបង្ហាញជាភស្តុតាងថា ទឹកកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ ដែលបារាំងបានកាត់ប្រគល់ទៅវៀតណាម ៕

**ប្រភពព័ត៌មានសារព័ត៌មានថ្មីៗ**

# បុណ្យចូលឆ្នាំខ្មែរ

**រៀបរាយដោយ មុនីផល ប៊ីង**
**បកប្រែដោយ ហង្ស តារាយុទ្ធ**



មុនីផល ប៊ីង

បុណ្យចូលឆ្នាំខ្មែរ ជាពេលដែលមនុស្សជំនាន់ចាស់ប្រមូលផ្តុំមិត្តភក្តិ និងក្រុមគ្រួសាររបស់ពួកគាត់ទាំងអស់ទៅលេងផ្ទះ ដើម្បីទៅរីករាយនឹងច្រៀងខារ៉ាអូខេខ្មែរដោយបើកសម្លេងខ្លាំងៗ ខណៈពេលដែលក្មេងជំនាន់ក្រោយលេងប៉ាតមុខគ្នាទៅវិញទៅមកជាមួយនិងពពុះសម្រាប់កោរពុកមាត់ និងម្សៅ ។ ទោះយ៉ាងណានោះថ្ងៃសម្រាកវប្បធម៌នេះគឺមិនមែនមានតែត្រឹមនេះទេ!

បុណ្យចូលឆ្នាំខ្មែរ គឺជាពិធីប្រពៃណីមួយដែលធ្វើឡើងរយៈពេល៣ថ្ងៃ ចាប់ពីខែមេសា ថ្ងៃទី១៣ ដល់ ទី១៥ មេសា ហើយប្រជាជនខ្មែរ នឹងចាប់ផ្តើមជួបជុំគ្នានាថ្ងៃនោះដើម្បីរំលឹកគុណនឹងប្រារព្ធពិធីរំលឹកគុណដល់ដូនតារបស់ពួកគេដែលបានចែកឋានទៅនៅឯវត្ត ។

វត្តខ្មែរសាមគ្គីសានទីការាមដែលមានទីតាំងស្ថិតនៅផ្លូវ៨៥ នៅភាគខាងជើង ធីងបូរូ Tyngsboro ក្រុង ឆេមហ្វដ (Chelmsford), ម៉ាសាឈូសេត MA បានស្វាគមន៏ប្រជាជនសហគមន៏ក្នុងតំបន់ ដើម្បីប្រារព្ធនូវពិធីនៃថ្ងៃឈប់សម្រាកមួយនេះ ជារៀងរាល់ឆ្នាំដែលចាប់ផ្តើមនៅថ្ងៃពុធទី១៣ ខែមេសាដល់ថ្ងៃអាទិត្យខែមេសាទី១៧ពីព្រោះថាថ្ងៃទាំងនេះគឺងាយស្រួលសម្រាប់ប្រជាជនបែងចែកនូវពេលវេលាការវិភាគរបស់ពួកគេ ។

ភ្ញៀវទេសចរជាញឹកញាប់បានពាក់នូវសម្លៀក

**តទៅទំព័រទី ២៨**

# Khmer New Year

**By Moniphal Bing**

Khmer New Year is a time when older generations gather all their friends and family to their house and joyfully sing Khmerkaraoke, all the way to maximum volume, while younger generations are whipping each other humorously with shaving cream and baby powder. However, that is not always the case for this cultural holiday!





Khmer New Year is traditionally celebrated in three days, April 13-15, when Cambodian family comes together and honor their ancestralceremony at the Buddhist temple. Wat Khmer Samaki Santikaram Temple, located at 85 Tyngsboro Road at North Chelmsford, MA, is welcoming the local community to celebrate the annual holiday, which begins on WednesdayApril 13th through Sunday April 17th, since these availabilities are much easier for people to find the most convenient schedule of their time.

Visitors have often worn traditional clothing or semi-formal western clothing and donate cooked authentic meals, respectively wrapped with plastic sheet and ceramic plate, and sometime wrapped with tin foil and aluminum tray,to the temple for prosperity and good fortunate. They also have the option to donate money to the temple for an exchange of prayer and sacred blessing. Whether you are a spiritual believer or a person who is genuinely curious despite of your ethnicity, the temple is a perfect opportunity to experience **Continued to Page 21**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ស្របពេលលោក កឹម សុខា មានរឿងអាស្រូវផ្លូវភេទ មជ្ឈដ្ឋានជាច្រើនរំឭកករណី ពិសិដ្ឋ ពិលីកា

**ដោយអេឡិក វិល្លឹមមីនស៍ និង គីម ចាន់** | **March 28, 2016**

អ្នកស្រី ពិសិដ្ឋ ពិលីកា គឺជាអ្នករបាំប្រពៃណី និងជាតារាភាពយន្តស្រីល្បីល្បាញបំផុតនៅប្រទេសកម្ពុជា។ ជាតារាភាពយន្តស្រីវ័យក្មេងក្នុងទសវត្សរ៍ឆ្នាំ១៩៨០ភាពល្បីល្បាញរបស់អ្នកស្រីបានឈានដល់កម្រិតថ្មីមួយទៀតក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ខណៈអ្នកស្រីបង្ហាញមុខក្នុងឧស្សាហកម្មវីដេអូតន្ត្រីខារ៉ាអូខេដ៏កាក់កប។

ហេតុដូច្នេះហើយទើបបានជាករណីឃាតកម្មដ៏រន្ធត់លើអ្នកស្រីនៅព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៩ ដែលត្រូវខ្មាន់កាំភ្លើងបាញ់សម្លាប់នៅខាងមុខផ្សារអូរឫស្សី ក្នុងរាជធានីភ្នំពេញ ជិតក្មួយស្រីវ័យ៧ឆ្នាំរបស់ខ្លួនបានបង្កការតក់ស្លុតទូទាំងប្រទេសនោះ គឺដោយសារតែគ្មានជនល្មើសណាម្នាក់ត្រូវបានចាប់ខ្លួន។

ពាក្យចចាមអារ៉ាមបានលេចឮសុះសាយនៅរយៈពេលប៉ុន្មានខែក្រោយមកតារារូបនេះត្រូវភរិយារបស់មន្ត្រីជាន់ខ្ពស់មួយរូបបញ្ជាឱ្យសម្លាប់ចោលដោយសារផ្ទុះកំហឹងខ្លាំងបន្ទាប់ពីដឹងថា អ្នកស្រីមានស្នេហាលួចលាក់ជាមួយប្តីរបស់ខ្លួន។

បន្ទាប់មកទស្សនាវដ្ដី L' Express ចេញផ្សាយប្រចាំសប្តាហ៍ដ៏ពេញនិយមរបស់បារាំងបានចុះផ្សាយអត្ថបទមួយដែលដកស្រង់សៀវភៅកំណត់ហេតុកត់ត្រាដោយអ្នកស្រី ពិសិដ្ឋ ពិលីកា ដែលទំនងជារៀបរាប់ពីការលួចជួបគ្នារាប់ឆ្នាំរបស់អ្នកស្រីជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងការបែកធ្លាយរឿងស្នេហាលួចលាក់នេះដល់លោកស្រី ប៊ុន រ៉ានី ភរិយារបស់លោក។

លោកនាយករដ្ឋមន្ត្រី និងជំទាវទី១ បានច្រានចោលការអះអាងទាំងនេះដាច់អហង្ការ ហើយបានបន្ទោសលោក សម រង្ស៊ី ថា ជាអ្នកប្រឌិតរឿងនេះដោយសារបងប្អូនថ្លៃស្រីរបស់លោក សម រង្ស៊ី ធ្វើការឱ្យទស្សនាវដ្ដី L' Express ប៉ុន្តែមិនដែលប្ដឹងទស្សនាវដ្ដីនេះពីបទបរិហារកេរ្តិ៍តាមការគំរាមជាសាធារណៈរបស់ខ្លួនឡើយ។

រឿងអាស្រូវផ្លូវភេទនេះបានផ្ទុះឡើងភ្លាមៗជាថ្មីម្ដងទៀតតាមរយៈការជជែកដេញដោលតាមប្រព័ន្ធអ៊ីនធឺណិតក្នុងរយៈពេល១ខែមកនេះ ខណៈនិស្សិតមួយក្រុម និងថ្មីៗនេះលោក ហ៊ុន សែន ផ្ទាល់បានធ្វើយុទ្ធនាការបន្ទោសលោក កឹម សុខា អនុប្រធានគណបក្សប្រឆាំងចំពោះការមានស្រីកំណាន់។

ខណៈអ្នកខ្លះអះអាងថារដ្ឋាភិបាលជាប់ពាក់ព័ន្ធនឹងការបញ្ចេញខ្សែអាត់សំឡេងសន្ទនាតាមទូរស័ព្ទរាប់សិបភាគដែលគេអះអាងថាជាសំឡេងរបស់លោក កឹម សុខា និងស្រីកំណាន់របស់លោក ហើយលោក ហ៊ុន សែន ថែមទាំងអះអាងថា មានភ័ស្តុតាងរូបថតក្នុងទូរស័ព្ទស្មាតហ្វូនរបស់លោកនោះ ព័ត៌មានជុំវិញស្នេហាលួចលាក់របស់នាយករដ្ឋមន្ត្រីលេចឮសុសសាយក្នុងចំណោមអ្នកប្រើប្រាស់បណ្ដាញទំនាក់ទំនងសង្គមដែលភាគច្រើនជាយុវវ័យ។



អត្ថបទនោះបានដកស្រង់កំណាព្យដែលលោក ហ៊ុន សែន សរសេរផ្ញើទៅអ្នកស្រី ពិសិដ្ឋ ពិលីកា និងសៀវភៅកំណត់ហេតុរៀបរាប់អំពីកាដូដែលលោកជូនអ្នកស្រីពិសិដ្ឋ ពិលីកា ដូចជាផ្ទះមួយនៅរាជធានីភ្នំពេញ និងប្រាក់រាប់សែនដុល្លារផ្ញើចូលគណនីធនាគារមួយដែលសៀវភៅកំណត់ត្រានោះបញ្ជាក់ថា ត្រូវលោកស្រី ប៊ុន រ៉ានី បង្កកទុក។

ជាឧទាហរណ៍មួយវគ្គនៃភាពយន្តឯកសារដែលបង្ហាញពីទិដ្ឋភាពកន្លែងកើតហេតុបន្ទាប់ពីការបាញ់សម្លាប់អ្នកស្រី ពិសិដ្ឋ ពិលីកា ត្រូវបានចែករំលែកត១គ្នាជាង១៣.៨០០ដង និងទស្សនា ៣៧០.០០០ដងតាមហ្វេសប៊ុក ចាប់តាំងពីវាត្រូវបានបង្ហោះដោយទំព័រប្រឆាំងរដ្ឋាភិបាល "Daily News" កាលពីថ្ងៃទី៩ ខែមីនា ពោលគឺមួយសប្តាហ៍បន្ទាប់ពីខ្សែអាត់ដំបូងនៃការសន្ទនាតាមទូរស័ព្ទរបស់លោក កឹម សុខា បានបែកធ្លាយ។

បន្ទាប់មកកាលពីសប្តាហ៍មុនក្រោយពីលោក ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយបានចាប់ផ្តើមការស៊ើបអង្កេតផ្លូវការថា តើលោក កឹម សុខា បានប្រាក់តាមវិធីណាដើម្បីសន្យាទិញផ្ទះឱ្យស្រីកំណាន់របស់លោកនោះ លោក ឆាំ ឆានី ដែលជាម្ចាស់ទំព័រហ្វេសប៊ុកប្រឆាំងដ៏មានប្រជាប្រិយភាពមួយបានលើកឡើងជាសាធារណៈអំពីស្តង់ដារពីរ។

សារនោះសរសេរថា "មានតែមួយក្នុងលោកៈ អង្គភាពប្រឆាំងអំពើពុករលួយស៊ើបរឿងស្នេហា" ហើយបន្តចោទសួរថា ហេតុអ្វីបានជាករណីអ្នកស្រី

តទៅទំព័រទី ១៨

# AMID LATEST SEX SCANDAL, MANY RECALL PISETH PILIKA

**by Alex Willemyns and Kim Chan | March 28, 2016**

PisethPilika was the most famous classical dancer and actress in Cambodia. A film starlet in the 1980s, she reached new levels of fame in the 1990s as the face of the booming karaoke music-video industry.

So her gruesome murder on the morning of July 6, 1999-gunned down in front of Phnom Penh's O'Russey market while standing beside her 7-year-old niece-sent shock waves through the country, not least because no one was ever arrested.

Then the popular French weekly L'Express dropped a bombshell: an article built around diary entries written by PisethPilika, apparently recounting her yearlong tryst with Prime Minister Hun Sen and the discovery of the affair by his wife, Bun Rany.

The story quoted poems allegedly written by Mr. Hun Sen to PisethPilika, and the diary mentions gifts he gave her, including a house in Phnom Penh and hundreds of thousands of dollars deposited into a bank account, funds which the diary says Ms. Rany froze.

The prime minister and first lady staunchly denied the claims, blaming opposition leader Sam Rainsy for fabricating the story-Mr. Rainsy's sister-in-law worked for L'Express-but never followed through on their public threat to sue the magazine for defamation.

The salacious story has suddenly resurfaced in online discussions over the past month as a group of students and, more recently, Mr. Hun Sen himself, have run a campaign to rebuke deputy opposition leader Kem Sokha for his own alleged recent mistresses.

With some claiming government involvement in the release of dozens of phone recordings purporting to be of Mr. Sokha and his lovers-and Mr. Hun Sen even claiming to possess photo evidence on his smartphone- information about the prime minister's own alleged affair is being spread among a mostly young population of social media users.

A section of a documentary featuring the crime scene after PisethPilika's shooting, for example, has been shared more than 13,800 times and viewed 370,000 times on Facebook since it was posted by the anti-government "Daily News" page on March 9-a week after the first alleged recordings of Mr. Sokha's calls leaked.

Then last week, after Anti-Corruption Unit chairman Om Yentieng launched an official inquiry into how Mr. Sokha got the funds to promise his mistresses houses, ChhamChhany, who curates a popular opposition Facebook page, publicly noted the double standard.

"Unique in the world: The Anti-Corruption Unit investigates love stories," the post says, going on to ask why the PisethPilika case did not receive the same level of scrutiny.

"Why don't you investigate that?" asked Mr. Chhany.

The popular "I Love Cambodia Hot News II" page also posted a photograph of the group of students who have led the campaign against Mr. Sokha.

"I'm wondering! Why hasn't this group demonstrated in search of justice for PisethPilika, PovPanhapich, Touch Srey Nich as well?" the page asked, referring to two other starlets shot after rumored affairs with high-ranking officials, leaving them both partially paralyzed.

While no evidence has come to light to prove that Mr. Sokha ever actually bought homes for his alleged mistresses, a trove of documents purporting to show Mr. Hun Sen's largesse was released on the Internet in 2002.

Three years after the publication of the L'Express article, PisethPilika's sister Sao **Continued to Page 23**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ក្រុមប្រឹក្សាក្រុងឡូវែលលុបចោលដំណើរទស្សនកិច្ចលោក ម៉ាណែត

**ដោយ Tej Parikh និងប៊ុត គឹមសាយ** | **March 31, 2016**

លោក ហ៊ុន ម៉ាណែត ជាកូនប្រុសច្បងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រឈមមុខនឹងដំណើរថយក្រោយមួយទៀតកាលពីថ្ងៃអង្គារចំពោះការប៉ុនប៉ងរបស់លោកក្នុងការទាក់ទងជាមួយសហគមន៍ខ្មែរ ក្រោយពីមន្ត្រីក្នុងក្រុងឡូវែល រដ្ឋម៉ាសេ្សតជូសេត ដែលមានជនជាតិខ្មែរអាមេរិកាំងប្រហែល៣០.០០០នាក់រស់នៅ គឺបានបោះឆ្នោតប្រឆាំងគម្រោងទស្សនកិច្ចរបស់លោកមកកាន់ទីក្រុងនេះនៅខែក្រោយ។

ការទាត់ចោលដំណើរទស្សនកិច្ចដោយក្រុមប្រឹក្សាក្រុងធ្វើឡើង បន្ទាប់ពីឧត្តមសេនីយ៍ឯក ម៉ាណែត បានប្រកាសថា លោកនឹងមិនចូលរួមក្បួនដង្ហែចូលឆ្នាំប្រពៃណីខ្មែរ ដែលគេអញ្ជើញលោកឱ្យធ្វើទស្សនកិច្ចក្នុងក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា ទេ ក្នុងពេលដែលមានការប្រឆាំងដាច់អហង្ការពីសំណាក់ខ្មែរអាមេរិកាំងជាច្រើននៅទីក្រុងនោះ។

ក្រុងឡូវែលមានប្រជាពលរដ្ឋខ្មែររស់នៅច្រើនបំផុតទីពីរនៅសហរដ្ឋអាមេរិកបន្ទាប់ពីក្រុងឡុងប៊ិច។ យោងតាមអត្ថបទមួយចុះផ្សាយក្នុងកាសែត ឡូវែល សាន់ ឱ្យដឹងថា មន្ត្រីក្រុមប្រឹក្សាក្រុងបានច្រានចោលដំណើរទស្សនកិច្ចលោកឧត្តមសេនីយ៍ឯក ម៉ាណែត ដែលមានគម្រោងមកនៅថ្ងៃទី១៦ និង១៧ ខែមេសា ក្នុងពេលនោះលោកមានគម្រោងជួបជាមួយមន្ត្រីក្រុង និងថ្លែងសុន្ទរកថា នៅឯភោជនីយដ្ឋានមួយក្នុងក្រុង ហើយប្រគល់ជូនបដិមាខ្មែរនាសតវត្សរ៍ទី១២។

សារព័ត៌មានបានរាយការណ៍ថា ពលរដ្ឋសហគមន៍ខ្មែររាប់រយនាក់ប្រជ្រៀតគ្នានៅក្នុងវិចិត្រសាលសារធារណៈនៅឯសាលាក្រុងឡូវែលនៅល្ងាចថ្ងៃអង្គារ ដោយគ្រវីសញ្ញាដែលសរសេរថា "សូមកុំរោយអំបិលលើដំបៅយើង" និង "ភាពផ្តាច់ការមិនមានក្នុងក្រុងឡូវែលទេ"។ ការតវ៉ាបានកើតឡើងក្រោយពីមានញត្តិមួយដែលចុះហត្ថលេខាដោយពលរដ្ឋ៥០០នាក់ដែលថ្កោលទោសចំពោះដំណើរទស្សនកិច្ចនោះ។

លោក ស៊ីនួន ខាំ ជាសកម្មជនជនជាតិខ្មែរ និងអ្នកក្រុងឡូវែល បាននិយាយក្នុងហ្វេសប៊ុកអមដោយរូបថតតវ៉ាថា "ជោគជ័យថ្ងៃនេះ... សម្រាប់ខ្មែរអាមេរិកាំងនៅក្នុងក្រុងឡូវែលរដ្ឋម៉ាសេ្សតជូសេតដែលថា ក្រុមប្រឹក្សាក្រុងបានបោះឆ្នោតជំទាស់នឹងការទទួលជាផ្លូវការនៃដំណើរទស្សនកិច្ច ហ៊ុន ម៉ាណែត មកកាន់ក្រុងនេះ"។

ការបង្ហោះនោះសរសេរថា "ខ្ញុំចង់បញ្ជាក់ម្តងទៀតថា ហ៊ុន ម៉ាណែត គឺមិនទទួលស្វាគមន៍ក្នុងក្រុងឡូវែល រដ្ឋម៉ាសេ្សតជូសេតទេ ដោយមានការសម្រេចជាឯកច្ឆន្ទក្នុងការទាត់ចោលវត្តមានរបស់លោក និងប្រតិភូផ្លូវការខ្មែរ"។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា ឧត្តមសេនីយ៍ឯក ម៉ាណែត ដែលចង់បញ្ចៀសការបង្កើតភាពប្រេះឆាររវាងអ្នកគាំទ្ររបស់លោក និងអ្នកប្រឆាំងនៅក្នុងសហរដ្ឋអាមេរិកនឹងមានវិធីផ្សេងទៀត។

លោក សុខ ឥសាន បានមានប្រសាសន៍ថា "ខ្ញុំមិនខ្វល់នឹងអ្នកដែលបោះឆ្នោតមិនគាំទ្រឯកឧត្តម ហ៊ុន ម៉ាណែត ទេ។ លោកបានប្រកាសនៅលើហ្វេសប៊ុករួចហើយថា លោកនឹងទៅសហរដ្ឋមេរិកពេលចូលឆ្នាំខ្មែរ។ អ្នកខ្លះស្វាគមន៍លោក ហើយអ្នកខ្លះមិនស្វាគមន៍ទេ គឺលោកនឹងអញ្ជើញទៅកន្លែងផ្សេងវិញ"។

លោក អ៊ូ វីរៈ អ្នកវិភាគនយោបាយបានមានប្រសាសន៍ថា ប៉ុន្តែសម្រាប់បុរសម្នាក់ដែលមនុស្សមួយចំនួនចាត់ទុកថាជាអ្នកស្នងតំណែងពីឪពុករបស់លោក ហើយដែលទទួលភារកិច្ចកាលពីឆ្នាំមុនដើម្បីដឹកនាំកិច្ចប្រឹងប្រែងទាក់ទងសហគមន៍ក្រៅប្រទេសរបស់គណបក្សប្រជាជនកម្ពុជានោះ ការច្រានចោលមួយនេះមានន័យថាជាការឡកមកវិញប្រឆាំងនឹងយុទ្ធនាការទំនាក់ទំនងសាធារណៈជាអន្តរជាតិរបស់គណបក្សកាន់អំណាច។

លោក អ៊ូ វីរៈ បានមានប្រសាសន៍ថា "តាមធម្មតា មនុស្សមានលុយ និងអំណាចរំពឹងថាមានគេទទួលស្វាគមន៍ដោយកម្រាលព្រំក្រហម។ ខ្ញុំមិនដឹងថា យុទ្ធសាស្ត្ររដ្ឋាភិបាលធ្វើយ៉ាងម៉េចទេ ប៉ុន្តែគេបានធ្វើកំហុសមួយដោយសន្មតថាពលរដ្ឋនឹងឆាប់ជឿណាស់"។

លោក អ៊ូ វីរៈ ដែលលោកផ្ទាល់ជាជនជាតិខ្មែរអាមេរិកាំង បានមានប្រសាសន៍ថា ឧត្តមសេនីយ៍ឯក ម៉ាណែត គឺជានិមិត្តរូបចំពោះអ្វីដែលខ្មែរអាមេរិកាំងជាច្រើនដែលបានចាកចោលប្រទេសក្នុងទសវត្សរ៍ឆ្នាំ១៩៨០ បន្តមានផ្ទាក់ផ្ទាំងក្នុងចិត្ត។

អ្នកវិភាគរូបនេះបាននិយាយថា "ខ្មែរនៅអាមេរិកត្រូវលងដោយអតីតកាល ពោលគឺភាគច្រើននៅតែមើលឃើញរដ្ឋាភិបាលលោក ហ៊ុន សែន ថាជាអាយ៉ងរបស់វៀតណាម ។ គេមានចំណុចដែលត្រូវសាកល្បង។ ប៉ុន្តែជាគោលនេះគឺជាការឡកមកវិញទល់នឹងរដ្ឋាភិបាល"។



Cambodian-American protesters fill a public gallery at Lowell City Hall in Massachusetts on Tuesday evening in a photograph posted to the Facebook page of Synoun Kham.

# LOWELL CITY COUNCIL CALLS OFF MANET'S NEW YEAR VISIT

**by Tej Parikh and ButhKimsay** | **March 31, 2016**

Hun Manet, Prime Minister Hun Sen's eldest son, faced another setback on Tuesday in his attempts to engage with the Cambodian diaspora, after officials in Lowell, Massachusetts-home to about 30,000 Cambodian-Americans-voted against his proposed visit to the city next month.

The City Council's rejection comes days after Lieutenant General Manet announced he would not be attending a Khmer New Year parade he was invited to in Long Beach, California, amid vehement opposition from many of the city's Cambodian-Americans.

Lowell is home to the U.S.' second-largest Cambodian population behind Long Beach. According to an article in the Lowell Sun newspaper, City Council officials denounced Lt. Gen. Manet's visit planned for April 16 and 17, during which he was scheduled to meet with city officials, deliver a speech at a local restaurant and donate a 12th-century Khmer statue.

Hundreds of Cambodian community members packed into a public gallery at Lowell City Hall on Tuesday evening, waving signs saying "Don't pour salt on our wounds" and "Dictatorship does not belong in Lowell," the newspaper reported.

The protest followed a petition signed by 500 residents condemning the visit.

"Success today…for Cambodian-Americans in the city of Lowell Massachusetts that the city councilors voted to oppose the official reception of Hun Manet's visit to the city," Synoun Kham, a Cambodian activist and Lowell resident, said in a Facebook post accompanied by photographs of the protest.

"I want to reiterate that Hun Manet is not welcome in Lowell Massachusetts with [the] motion unanimously to reject his [presence] and Cambodian official delegations," the post said.

CPP spokesman Sok Eysan said Lt. Gen. Manet, wanting to avoid creating a schism between his supporters and detractors in the U.S., would make alternate arrangements.

"I do not care about the people who voted not to support His Excellency Hun Manet," Mr. Eysan said. "He has already announced on his Facebook either way that he will go to the U.S.A. during the Khmer New Year."

"Some people welcome him and some don't-he will just go somewhere else."

But for the man who some have touted as a possible successor to his father, and who was tasked last year with leading the CPP's foreign outreach efforts, another rejection amounts to a significant "backfire" against the ruling party's international public relations campaign, said political analyst Ou Virak.

"People from money and power usually expect red-carpet treatment," he said. "I don't know what the government's strategy was, but they made a mistake to assume people would be so gullible."

Mr. Virak, himself a U.S. citizen, said Lt. Gen. Manet symbolized what many Cambodian-Americans who left the country in the 1980's continued to resent.

"The Cambodians in [the] U.S. are haunted by the past-many still see the Hun Sen government as a puppet of the Vietnamese," he said.

"They get points for trying. But this is basically a backfire against the government."

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឲ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# អង្គភាពប្រឆាំងអំពើពុករលួយថា ឯកអគ្គរាជទូតខ្មែរប្រចាំកូរ៉េខាងត្បូងមានប្រាក់៧.២លានដុល្លារ

**ដោយ បែន សុខហ៊ាន** | April 7, 2016

អង្គភាពប្រឆាំងអំពើពុករលួយបានចេញសេចក្តីប្រកាសព័ត៌មានមួយថ្ងៃនេះ ដោយនិយាយថា លោក ស៊ុត ឌីណា ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសកូរ៉េខាងត្បូងដែលត្រូវសាកសួរនៅឯតុលាការក្រុងភ្នំពេញថ្ងៃនេះទាក់ទិននឹងបណ្តឹងពុករលួយ គឺមានប្រាក់នៅក្រៅធនាគារជាសាច់ប្រាក់៧.២លានដុល្លារអាមេរិក និងមាស៣៣៩តម្លឹង។

សេចក្តីប្រកាសព័ត៌មាននិយាយថា "អ.ប.ព. គ្រាន់តែសូមជម្រាបជូនសាធារណជនយ៉ាងខ្លីថា ឯកឧត្តម ស៊ុត ឌីណា មានលុយដុល្លារជាសាច់ប្រាក់នៅក្រៅធនាគារ៧.២លានដុល្លារអាមេរិក មានន័យថា មានកំណើនសាច់ប្រាក់ចុងក្រោយនេះចំនួន៣លានដុល្លារអាមេរិក (ឆ្នាំ២០១៣ ឯកឧត្តម ស៊ុត ឌីណា មានចំនួន៤.២លានដុល្លារអាមេរិក)"។

